# អង្គនៃនិច្ចសីល

បាណាតិបាត មានអង្គ៥

- ១ - បាណោ សត្វមានជីវិត
- ២ - បាណសញ្ញិតា សេចក្តីដឹងថាសត្វមានជីវិត។
- ៣ -វធកចិត្តំ គិតនឹងសំលាប់
- ៤ -អុបក្កមោ ព្យាយាមនឹងសំលាប់
- ៥ - តេន មរណំ សត្វស្លាប់ដោយព្យាយាម។

អទិន្នាទាន មានអង្គ៥

- ១ - បរបរិត្តហិតំ ទ្រព្យដែលមានម្ចាស់គេហួងហែងរក្សា។
- ២ - បរបរិត្តហសញ្ញិតា សេចក្តីដឹងថាទ្រព្យមានម្ចាស់គេហួងហែងរក្សា។
- ៣ - ថេយ្យចិត្តំ គិតនឹងលួច។
- ៤ - អុបក្កមោ ព្យាយាមនឹងលួច។
- ៥ - តេនហរណំ លួចបានមកដោយព្យាយាមនោះ

កាមេសុមិច្ឆាចារ មានអង្គ៤

- ១ - អគមនីយដ្ឋានំ ស្រ្តីដែលមិនគួរគប់រកគឺស្ត្រីដែលមានគេហួងហែង រក្សា
- ២ - តស្មឹ សេវនចិត្តំ គិតនឹងសេពមេថុនធម្មនឹងស្រ្តីនោះ។
- ៣ - អុបក្កមោ ព្យាយាមនឹងសេពនូវមេថុនធម្ម។
- ៤ - មគ្គេន មគ្គប្បដិបាទនំ ញ៉ាំងមគ្គ និងមគ្គអោយដល់គ្នា។

មុសាវាទ មានអង្គ៤

- ១ - អតថំវត្ថុ វត្ថុមិនពិត។
- ២ - វិសំវាទនចិត្តំ គិតនឹងពោលពាក្យអោយខុស។
- ៣ - តជ្ជោ វាយាមោ ព្យាយាមនឹងពោលអោយខុស។
- ៤ - បរស្សតទត្ថវិជាននំ ញ៉ាំងអ្នកដទៃអោយដឹងច្បាស់នូវសេចក្តីនោះ។

សុរាមេរយមានអង្គ៤

- ១ - មជ្ជនីយវត្ថុវត្ថុជាទីតាំងនៃសេចក្តីស្រវឹង គឺសុរានិងមេរ័យ។
- ២ - បាតុកម្យតាចិត្តំ គិតបំរុងនឹងផឹក
- ៣ -តជ្ជោ វាយាមោ ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ។
- ៤ - តស្សបានំ បានផឹកទឹកស្រវឹងនោះអោយកន្លងបំពង់កចូលទៅ។

អង្គនៃអុបោសថសីល

អង្គនៃសិក្ខាបទ បាណា អទិន្នា មុសា សុរា មានដូចនៅក្នុងនិច្ចសីលដែរ។

អព្រហ្មចរិយា មានអង្គ៤

- ១ - ភេទនវត្ថុ វត្ថុជាទីទំលាយនូវសីល គឺទ្វារទាំង៣០ចំពោះទ្វារណានិមួយ
- ២ - សេវនចិត្តំ គិតនឹងសេព។
- ៣ - តជ្ជោ វាយាមោ ព្យាយាមនឹងសេពនូវមេថុនធម្មនោះ។
- ៤ - មគ្គេន មគ្គប្បដិបាទនំ ញ៉ាំងមគ្គ និងមគ្គអោយដល់គ្នា។

វិកាលភោជន មានអង្គ៣

- ១ -វិកាលោ កាលខុស គឺព្រះអាទិត្យជ្រេទៅហើយដរាបដល់អរុណរះ។
- ២ -យាវកាលិកំ របស់ដែលគួរបរិភោគបានក្នុងកាល គឺតាំងពីអរុណរះឡើងដរាបដល់ថ្ងៃ

ត្រង់។

- ៣ -អជ្ឈោហរណំ បានលេបចូលទៅក្នុងបំពង់ក។

នច្ចគីតព្រមទាំង មាលារូមជាសិក្ខាបទមួយមានអង្គ៦

- ១-នច្ចគីតាទិ ការល្បែងមានរាំ និងច្រៀងជាដើម
- ២ -កត្តុកម្យតាចិត្តំ គិតបំរុងនឹងធ្វើ
- ៣ -សុតទស្សនត្ថាយគមនំ ទៅដើម្បីស្តាប់រឺមើលហើយបានស្តាប់រឺមើល
- ៤ - មាលាទិ វត្ថុសំរាប់ប្រដាប់កាយមានកំរងផ្កាជាដើម
- ៥ -ធារណច្ឆន្ទតា សេចក្តីប្រាថ្នា នឹងប្រដាប់តាក់តែង។
- ៦ - តស្សធារណំ បានប្រដាប់តាក់តែងនូវវត្ថុសំរាប់ប្រដាប់កាយមានផ្កា កំរងជាដើមនោះ។

អុច្ចាសយន មានអង្គ៣

- ១-អុច្ចាសយនមហាសយនំ ទីដេកទីអង្គុយដ៏ខ្ពស់ដ៏ប្រសើរហួសប្រមាណ
- ២-បរិភោគ្គចិត្តំ គិតនឹងដេករឺអង្គុយ។
- ៣ - បរិភោគករណំ បានដេករឺអង្គុយ។

កាលបើអុបាសកអុបាសិកាប្រព្រឹត្តអោយកន្លងនូវសិក្ខាបទណាៗ លុះតែព្រមដោយ អង្គក្នុងសិក្ខាបទ នោះៗ ទើបបានឈ្មោះថាកន្លង បើមិនទាន់ព្រមដោយអង្គនោះ ក៏មិនបានឈ្មោះថាកន្លងនូវសិក្ខាបទនោះ ទេ។

អង្គនៃនិច្ចសីល និង អុបោសថសីល ចប់តែប៉ុណ្ណេះ។